# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៧០២ សហវ.៣៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២

## សេចក្តីជូនដំណឹង

### ស្តីពី

### ការទូទាត់ប្រាក់បំណុលពន្ធរដ្ឋ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងរំលឹកជាចុងក្រោយបង្អស់ដល់លោក-លោកស្រី ជានាយកក្រុមហ៊ុនដែលជំពាក់បំណុលពន្ធរដ្ឋ សូមអញ្ជើញមកធ្វើការទូទាត់សងបំណុលពន្ធអោយបានចប់សព្វគ្រប់មុនថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០២ ជាកំហិត ។ ករណីមិនបានមកទូទាត់បំណុលពន្ធតាមកាលបរិច្ឆេទខាងលើនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងអនុវត្តយ៉ាងតឹងរឹងបំផុតតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធទៅតាមករណីនីមួយៗដែលរួមមាន : ការឃាត់ទុកគណនីនៅធនាគារ ឬ រតនាគារជាតិ បញ្ឈប់រាល់ប្រតិបត្តិការនាំចេញ-នាំចូល ទុកជាមោឃៈនូវលិខិតអនុញ្ញាតិ និងអាជ្ញាប័ណ្ណផ្សេងៗ និង រឹបអូសទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនលោកដើម្បីធ្វើការដេញថ្លៃលក់យកប្រាក់មកទូទាត់បំណុលពន្ធ ប្រាក់ទោសទ័ណ្ឌព្រមទាំងប្រាក់ ចំណាយក្នុងការប្រមូលពន្ធ ។

អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជឿជាក់ថា លោក-លោកស្រី ប្រាកដជាបានយល់ដឹង និង យកចិត្តទុកដាក់បំពេញភារកិច្ចបង់បំណុលពន្ធជូនរដ្ឋតាមពេលវេលាកំណត់ខាងលើជាពុំខាន ។

សូមលោក-លោកស្រី ជ្រាបនិងអនុវត្តតាមច្បាប់កំណត់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់